# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតបំភ្លឺ

ខ្ញុំបាទឈ្មោះ **សិទ្ធិ កូសាំងស៊ីន** សូមធ្វើការបំភ្លឺជូនសាធារណៈជន នឹងបណ្តាសារព័ត៌មានទាំងអស់ ពាក់ព័ន្ធនឹងករណីរបស់ខ្ញុំបាទដែលត្រូវបុគ្គលឈ្មោះ **ហេង ប៊ុនទី** បានធ្វើការឃាត់ខ្លួនខ្ញុំបាទកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ និងករណីដែលបុគ្គលឈ្មោះ **យាង វុឌ្ឍពៅ** ធ្វើការយកលុយរបស់ខ្ញុំបាទក្នុងទំហំទឹកប្រាក់ចំនួន **៥០០០$ (ប្រាំពាន់)ដុល្លាអាមេរិក** គឺជាករណីពីរផ្សេងគ្នាដាច់ដោយឡែកពីគ្នា ហេតុនេះខ្ញុំបាទនឹងធ្វើការបំភ្លឺដូចតទៅនេះ៖

**ករណីទី១ ករណីរបស់ខ្ញុំបាទត្រូវបុគ្គលឈ្មោះ ហេង ប៊ុនទី បានធ្វើការឃាត់ខ្លួនខ្ញុំបាទកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១៖**

ជាបឋមខ្ញុំបាទ សូមធ្វើការថ្លែងអំណរអរគុណទៅដល់បណ្តាអ្នកសារព័ត៌មានទាំងអស់ដែលបានធ្វើការផ្សព្វផ្សាយក្នុងគោលបំណងជួយស្វែងរកយុត្តិធម៌ដល់រូបខ្ញុំបាទ និងសូមអរគុណចំពោះអង្គភាពកងរាជអាវុធហត្ថលើផ្ទៃប្រទេសចំពោះការធ្វើសេចក្តីប្រកាសជាព័ត៌មានកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ ចំពោះករណីដែលបុគ្គលឈ្មោះ **ហេង ប៊ុនទី** ជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះសីហនុបានធ្វើការឃាត់ខ្លួនខ្ញុំបាទកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ ។ ខ្ញុំបាទសូមធ្វើការបកស្រាយថា នៅក្នុងករណីដែលបុគ្គលឈ្មោះ **ហេង ប៊ុនទី** បានធ្វើការឃាត់ខ្លួនខ្ញុំបាទនេះ គឺមិនមានទំនាក់ទំនងអ្វីជាមួយនឹងការយកប្រាក់ចំនួន**៥០០០$**ពីខ្ញុំបាទនោះឡើយ ។ ខ្ញុំបាទបានឃើញអង្គភាពសារព័ត៌មានមួយចំនួន មានការផ្សព្វផ្សាយធ្វើឱ្យមានការភាន់ច្រឡំថាបុគ្គលឈ្មោះ **ហេង ប៊ុនទី** ជាមេបញ្ជាការកងរាជអាវុធហត្ថ ខេត្តព្រះសីហនុ បានធ្វើការឃាត់ខ្លួននិងទាមទារប្រាក់ចំនួន ៥០០០$ ដែលនេះផ្ទុយពីការពិតទៅនឹងអ្វីដែលខ្ញុំបាទបានធ្វើការសម្ភាសន៍ ។ ជាក់ស្តែង នៅក្នុងកិច្ចសម្ភាសន៍របស់ខ្ញុំបាទ តាមរយៈសារព័ត៌មាន **MTV Today** បានធ្វើការចុះផ្សាយកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ដែលមានថិរវេលាចំនួនមួយម៉ោងនេះ ទើបជាការបកស្រាយដ៏ពេញលេញរបស់ខ្ញុំបាទ ហើយចំពោះបណ្តាសារពត៌មានផ្សេងទៀតដែលបានសង្ខេបខ្លឹមសារ យកទៅផ្សព្វផ្សាយអាចនឹងធ្វើឱ្យមានការភាន់ច្រឡំចំពោះករណីនេះ ដែលនាំឱ្យខូចទៅដល់កេរ្តិ៍ឈ្មោះរបស់អង្គភាព កងរាជអាវុធហត្ថទាំងមូល (ខ្ញុំបាទសូមធ្វើការបដិសេធថា ការផ្សព្វផ្សាយនោះមិនត្រឹមត្រូវទេ)។ ហើយខ្ញុំបាទសូមបញ្ជាក់ផងដែរថា រថយន្តរបស់បុគ្គលឈ្មោះ **ហេង ប៊ុនទី** គឺមិនមែនជាឡានក្បួនដូចជាការផ្សព្វផ្សាយផ្សេងៗនោះឡើយ។

ម្យ៉ាងវិញទៀតនៅក្នុងសេចក្តីប្រកាសជាព័ត៌មានរបស់អ្នកនាំពាក្យកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានធ្វើការលើកឡើងថា ខាងកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានទទួលលិខិតរបស់ខ្ញុំបាទនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១។ ប៉ុន្តែភាពពិតជាក់ស្តែង ខ្ញុំបាទបានដាក់លិខិតជាពាក្យបណ្តឹងជូនទៅ **ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងករយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស** តាមរយៈខុទ្ទកាល័យកងរាជអាវុធហត្ថមានវាយត្រាចូលលេខ ១៤២ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១៦ និង ២៦នាទី មកម្លេះ។ ហើយចំពោះការលើកឡើងថា មន្ត្រីនគរបាលយុត្តិធម៌ (កូនចៅរបស់បុគ្គល **ហេង ប៊ុនទី**) នៃកងរាជអាវុធហត្ថស្រុកកំពង់សិលា បានធ្វើការនាំខ្លួនខ្ញុំបាទ និងឈ្មោះ **ប៊ុយ ឈុយ** ដើម្បីធ្វើការស្តាប់ចម្លើយ តើការនាំខ្លួនដើម្បីធ្វើការស្តាប់ចម្លើយនេះអំពីបទល្មើសអ្វី? នឹងមានសញ្ញាណនៃបទល្មើសព្រហ្មទណ្ឌត្រង់ចំណុចណាដែលលេចឡើងនៅក្នុងអំឡុងពេលនោះ? ចំណែកឯបុគ្គលឈ្មោះ **ហេង ប៊ុនទី** ជាអ្នកបញ្ជា ឱ្យខាងមន្ត្រីនគរបាលយុត្តិធម៌ (កូនចៅរបស់ខ្លួន) វាយខ្នោះ និងធ្វើការឃាត់ខ្លួនខ្ញុំបាទនោះ (តែពេលនោះកូនចៅ មិនហ៊ានវាយខ្នោះខ្ញុំទេ) តើរូបខ្ញុំបាទមានកំហុសអ្វី? សូមធ្វើការបំភ្លឺ! តើការវិនិច្ឆ័យរបស់លោកមេបញ្ជាការកងរាជអាវុធខេត្តព្រះសីហនុថា ខ្ញុំបាទបានប្រព្រឹត្តបទល្មើស ដែលឈានទៅដល់ការបង្ខំឲ្យឡើងឡានធ្លាក នាំខ្លួនទៅអធិការដ្ឋានស្រុកកំពង់សិលាដោយសំអាងលើកត្តាអ្វីខ្លះ? តើមកពីការពាក់ម៉ាសរបស់ខ្ញុំបាទ ឬការជិះឡានពីក្រោយឡាន

របស់បុគ្គលឈ្មោះ **ហេង ប៊ុនទី** ដោយខុសច្បាប់? ហេតុអ្វីបានជាលោកធ្វើការសន្និដ្ឋានថា ខ្ញុំបាទមានបំណងប៉ុនប៉ងធ្វើឃាតដោយការជិះតាមក្រោយឡានរបស់លោក ហើយពាក់ម៉ាសដូចនីនចារ? តើការជិះឡាននៅពីក្រោយចំងាយប្រមាណជា ៥០ម៉ែត្រពីរថយន្តរបស់លោកនៅលើផ្លូវជាតិលេខ០៤ អាចសន្និដ្ឋានថាជាការតាមធ្វើឃាតដែរ រឺទេ? ហើយខ្ញុំបាទធ្វើការពាក់ម៉ាសប្រភេទនេះ គឺដើម្បីការពារកូវិតស្របតាមក្រសួងសុខាភិបាលណែនាំ ហើយការពាក់ម៉ាស់ប្រភេទអី ក៏មិនមានបំរាម ឬច្បាប់ណាហាមឃាត់មិនអោយពាក់ម៉ាសបែបនេះ បែបនោះ នោះដែរ!.... ។ បន្ថែមពីនេះទៀត នៅពេលដែលកំពុងឃាត់ខ្លួន ខ្ញុំបាទបានបង្ហាយនូវលិខិតបេសកម្មដើម្បីបញ្ជាក់ថា ខ្ញុំបាទជាមន្ត្រីគយ និងនៅពេលដែលបានឆែកឆេរក្នុងរថយន្ត គឺមិនមានអាវុធ ឬវត្ថុណាដែលអាចធ្វើឃាតបានដូចជាការចោទប្រកាន់នោះឡើយ គឺមានតែឯកសណ្ឋានមន្ត្រីគយតែប៉ុណ្ណោះ។ ដូច្នេះ តើហេតុអ្វីបុគ្គលឈ្មោះ **ហេង ប៊ុនទី** នៅតែបន្តធ្វើការឃាត់ខ្លួន និងបង្ខំខ្លួនខ្ញុំយកទៅសួរចម្លើយនៅបញ្ជាការដ្ឋានស្រុកកំពង់សិលាជាបន្តទៀត អស់រយៈពេលជាង **៣**ម៉ោង? មិនតែប៉ុណ្ណោះ នៅពេលដែលបញ្ចប់ការស្តាប់ចម្លើយរបស់ខ្ញុំ បញ្ជាការដ្ឋានស្រុកកំពង់សិលាបែរជាលើកថាជាការភាន់ច្រឡំទៅវិញ ហើយថែមទាំងដកហូតលិខិតបេសកម្មរបស់ខ្ញុំបាទអស់រយៈពេលជាច្រើនថ្ងៃរហូតដល់មានការស្នើសុំពីប្អូនប្រុសរបស់ខ្ញុំបាទ ទើបប្រគល់ឲ្យមកវិញ។ ចំពោះករណី ដែលបុគ្គលឈ្មោះ **ហេង ប៊ុនទី** ធ្វើមកលើរូបខ្ញុំនេះ គឺធ្វើឱ្យខ្ញុំបាទមានការឈឺចាប់ខ្លាំងណាស់ ក្នុងនាមជាមន្ត្រីរាជការ និងជាមន្ត្រីនគរបាលយុត្តិធម៌មួយរូបដែរ ដែលបានបម្រើការងារប្រមូលពន្ធជូនជាតិ មាតុភូមិអស់រយៈពេលជាង **៣០**ឆ្នាំកន្លងមកហើយនេះ តែត្រូវទទួលរងនូវអំពើបំពានទាំងអសីលធម៌ និងច្បាប់មកលើរូបខ្ញុំទាំងគឃ្លើនទៅវិញ!.... ហើយខ្ញុំបាទក៏មិនបានធ្វើការទាមទារអ្វីឱ្យហួសហេតុនោះទេ គឺគ្រាន់តែចង់ឱ្យបុគ្គលឈ្មោះ **ហេង ប៊ុនទី** ដែលជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះសីហនុរូបនេះ ធ្វើការបំភ្លឺជាលាយលក្ខអក្សរមកឱ្យខ្ញុំបាទ តាមរយៈអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាតែប៉ុណ្ណោះ ដើម្បីរក្សានូវកិត្តិយសនិងតម្លៃជាមន្ត្រីគយក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌មួយរូបដែរនោះ។

**ករណីទី២ ករណីរបស់ខ្ញុំបាទត្រូវបុគ្គលឈ្មោះ យាង វុឌ្ឍពៅ ធ្វើការយកលុយរបស់ខ្ញុំបាទប្រាក់ចំនួន ៥០០០$៖**

នៅក្នុងកិច្ចសម្ភាសន៍របស់ឈ្មោះ **យាង វុឌ្ឍពៅ** និងអ្នកនាង **ពិសី** កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១០ ព្រឹកនោះឃើញថា ការអះអាងរបស់ឈ្មោះ **យាង វុឌ្ឍពៅ** អំពីទឹកប្រាក់របស់ខ្ញុំបាទនេះ គឺផ្ទុយពីការពិតទាំងស្រុង។ លោក **យាង វុឌ្ឍពៅ** បានធ្វើការលើកឡើងថា បានយកលុយរបស់ខ្ញុំបាទកាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ចំនួន ៤០០០ $ ដើម្បីធ្វើការចាត់ចែងនៅលើអាជីវកម្មដីគ្រួស ដូច្នេះតើលោកអាចបញ្ជាក់ឱ្យច្បាស់ថាទៅលើផ្នែកអ្វីមួយនៅក្នុងអាជីវកម្មនេះ? តើទៅលើកម្មករ ទៅលើម្ចាស់ដី ទៅលើគ្រឿងចក្រ ឬក៏លោកបានយកលុយទាំងនេះទៅប្រគល់ឱ្យបុគ្គលណាម្នាក់ដែលជាមន្ត្រីជំនាញអ្វីមួយនោះ? យោងតាមសម្តីរបស់អ្នកនាង **ពិសី** បានផ្ញើមកប្រាប់មកខ្ញុំយ៉ាងច្បាស់ថា លោក **យាង វុឌ្ឍពៅ** ពិតជាបានយកលុយទាំងនេះទៅឱ្យបុគ្គលមួយរូបនោះពិតប្រាកដមែន? ហើយនៅក្នុងកិច្ចសម្ភាសន៍នេះ ហេតុអ្វីអ្នកនាងពិសីមិនធ្វើការបញ្ជាក់នឹងអះអាងដូចទៅនឹងអ្វីដែលបានមកប្រាប់ខ្ញុំបាទ? បន្ថែមពីលើនេះទៀត លោក **យាង វុឌ្ឍពៅ** បានលើកឡើងថា ខ្លួនមិនដែលស្គាល់បុគ្គលឈ្មោះ **ហេង ប៊ុនទី** ទេ ចុះកាលដែលលោកប្រាប់ខ្ញុំបាទថា ខ្លួនត្រូវជាកូនធម៌របស់ម្តាយរបស់បុគ្គលឈ្មោះ **ហេង ប៊ុនទី** នោះ និងបានឱ្យខ្ញុំបាទនិយាយទូរសព្ទជាមួយគាត់កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ តើគាត់នោះជានរណាឱ្យពិតប្រាកដ? ខ្ញុំបាទសូមធ្វើការបញ្ជាក់ថា រាល់អ្វីដែលខ្ញុំបានលើកឡើងខាងនេះ គឺសុទ្ធតែមានភស្តុតាងទាំងអស់។ រឿងអ្វីផ្សេងៗទៀត យើងនឹងដោះស្រាយគ្នាទៅតាមផ្លូវច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកសារពត៌មាន សាធារណជន និងបុគ្គលដែលពាក់ព័ន្ធមេត្តាជ្រាប។

ធ្វើនៅថ្ងៃច័ន្ទ ៥រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១
ហត្ថលេខានិងឈ្មោះ